អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងគ្រោះធម្មជាតិ**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖

ការហ្វឹកហាត់បង្កើតកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក៖

**វិទ្យាសាស្ត្រ** ៖ ការរស់នៅប្រចាំថ្ងៃ៖ លក្ខណៈមេឃនិងអាកាសធាតុ៖

**បុរេគណិត** ៖ រូបរាងនិងលំហ៖ បញ្ញាត្តិរូបរាងនិងលំហ៖

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖

កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេងល្បែងបានរឹងមាំល្អ។

**វិទ្យាសាស្ត្រ** ៖ វិជ្ជាសម្បទា៖ ប្រាប់បានផលវិបាកនៃបាតុភូត ធម្មជាតិ៖ ភ្លៀវ ផ្លេកបន្ទោរ រន្ទះផ្គរ ខ្យល់ ព្យុះ ទឹកជំនន់ រាំងស្ងួតជាដើម...។

**បុរេគណិត** ៖ បំណិនសម្បទា៖

កំណត់ទីតាំងវត្ថុធៀបទៅនឹងវត្ថុមួយផ្សេងទៀតដោយប្រើពាក្យដូចជា ខាងលើ ខាងក្រោម ខាងក្រោយ ខាងក្នុង ខាងឆ្វេង ខាងស្តាំជាដើម...។

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ មិនមែនសម្ភារសម្រាប់លេងទេ

**ការរៀបចំ** ៖ ត្រៀមពាក្យនិងរបៀបលេងឱ្យបានច្បាស់មុននឹងលេង ជៀងវាងភ្លេចពេលលេង។

**សេចក្តីណែនាំ** ៖

1. គ្រូត្រូវមានមេរៀនមួយអំពីគ្រោះធម្មជាតិ និងបាតុភូតធម្មជាតិផ្សេងៗ ដូចជាការរញ្ជួយដី ទឹកជំនន់ ពេលភ្លៀវមានផ្គររន្ទះ ខ្យល់ ជាដើម...សម្រាប់បង្រៀនកុមារជាមុនសិន ដើម្បីឱ្យកុមារបានយល់និងស្គាល់ឱ្យច្បាស់សិនជាការល្អប្រសើរ។
2. ប្រាប់កុមារឱ្យធ្វើកាយវិការនិងថាតាមពាក្យនីមួយៗជាមុនសិន។ មានដូចជា៖

១. ខ្យល់៖ លើកដៃឡើងលើទាំងពីរនិងធ្វើជារេចុះរេឡើងទៅវិញទៅមក

២. ភ្លៀង៖ ទះដៃឱ្យលឿននិងខ្លាំងៗ។

៣. ផ្គរលន់៖ ទន្រាំជើងឱ្យឮៗ និងខ្លាំងៗ។

៤. រញ្ជួយដី៖ ដាក់ដៃលើក្បាលហើយក្រាបចុះក្រោម។

៥. រន្ទះ៖ ទន្រាំជើងនិងទះដៃលឿនៗនិងខ្លាំងៗ។

3. បន្ទាប់ពីបានបង្ហាញកុមារនិងប្រាប់កុមារពីរបៀបធ្វើកាយវិការ គ្រូនាំកុមារលេងទាំងអស់តែម្តង
4. ល្បែងនេះអាចលេងម្តងទាំងអស់គ្នាម៉ង
5. គ្រូឡើងនៅខាងលើនិងបន្ទាប់មក ស្រែកពាក្យដែលមានខាងលើនោះ បន្ទាប់មក កុមារទាំងអស់ចាប់ផ្តើមធ្វើតាមពាក្យដែលអ្នកគ្រូបានស្រែកគឺជាកាស្រេច។
6. **បញ្ជាក់៖ ល្បែងនេះអាចឱ្យកុមារយល់ដឹងនិងអាចការពារខ្លួនពេលមានគ្រោះធម្មជាតិម្តងៗ។**